**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ពន្ធលើផ្ទាំងផ្សព្វផ្សាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អត្រាពន្ធនិងមូលដ្ឋានគិតពន្ធលើផ្ទាំងផ្សព្វផ្សាយគ្រប់ប្រភេទ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្សព្វផ្សាយតាមគ្រប់រូបភាពទាំងចល័ត និងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

សម្រាប់គោលដៅនៃអនុក្រឹត្យនេះ ពាក្យ **ផ្ទាំងផ្សព្វផ្សាយ** សំដៅដល់៖

១- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីកៅស៊ូ ក្រដាសធម្មតា កំណាត់សំពត់ ឬវត្ថុផ្សេងៗ។

២- ស្លាកអាជីវកម្មដ្ឋានសម្រាប់ដាក់សម្គាល់ឈ្មោះ ទីតាំង ទីស្នាក់ការ ការិយាល័យ ឬទីកន្លែងប្រកបអាជីវកម្មនានា។

៣- ផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម។

**មាត្រា៤ .-**

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវអនុវត្តតាមប្រភេទ អត្រា និងលក្ខខណ្ឌបន្ថែម ដូចខាងក្រោម៖

<table>
<tr><th>លេខរៀង</th><th>ប្រភេទផ្ទាំងផ្សព្វផ្សាយ</th><th>អត្រាពន្ធ</th><th colspan="2">លក្ខខណ្ឌបន្ថែម</th></tr>
<tr><td colspan="5">១- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីក្រដាសធម្មតា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ</td><td>៥០០៛/ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ១ ៥០០៛/ទំព័រ</td></tr>
<tr><td>ខ</td><td>មានផ្ទៃក្រឡាលើសពី ៤០ដេស៊ីម៉ែត្រការ៉េ</td><td>៧០០៛/ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ២ ១០០៛/ទំព័រ</td></tr>
<tr><td colspan="5">២- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីកៅស៊ូ កំណាត់សំពត់ ឬវត្ថុផ្សេងៗ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ</td><td>៧០០៛/ផ្ទាំង</td><td colspan="2">បើមានអក្សរបរទេស ២ ១០០៛/ផ្ទាំង</td></tr>
<tr><td>ខ</td><td>មានផ្ទៃក្រឡាលើសពី ៤០ ដល់ ១០០ដេស៊ីម៉ែត្រការ៉េ "បើលើសពី ១០០ដេស៊ីម៉ែត្រការ៉េ គិតជាផ្ទាំងអក្សរ ឬផ្ទាំងរូបភាព"</td><td>១ ០០០៛/ផ្ទាំង</td><td colspan="2">បើមានអក្សរបរទេស ៣ ០០០៛/ផ្ទាំង</td></tr>
<tr><td colspan="5">៣- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>គ្មានពន្លឺលើកស្របដងផ្លូវ</td><td>១០០៛/ជម$^2$/ឆ្នាំ</td><td>២០០៛</td><td rowspan="2">បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ</td></tr>
<tr><td>ខ</td><td>គ្មានពន្លឺកែងដងផ្លូវ</td><td>១៥០៛/ជម$^2$/ឆ្នាំ</td><td>៣០០៛</td></tr>
<tr><td colspan="5">៤- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>មានពន្លឺលើកស្របដងផ្លូវ</td><td>២០០៛/ជម$^2$/ឆ្នាំ</td><td>៤០០៛</td><td rowspan="2">បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ</td></tr>
<tr><td>ខ</td><td>មានពន្លឺកែងដងផ្លូវ</td><td>២៥០៛/ជម$^2$/ឆ្នាំ</td><td>៥០០៛</td></tr>
<tr><td colspan="5">៥- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>គ្មានពន្លឺលើកស្របដងផ្លូវ</td><td>៥០០៛/ជម$^2$/ឆ្នាំ</td><td>១ ០០០៛</td><td rowspan="2">បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ</td></tr>
<tr><td>ខ</td><td>គ្មានពន្លឺកែងដងផ្លូវ</td><td>៧០០៛/ជម$^2$/ឆ្នាំ</td><td>១ ៤០០៛</td></tr>
<tr><td colspan="5">៦- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៣ នៃអនុក្រឹត្យនេះ</td></tr>
<tr><td>ក</td><td>មានពន្លឺលើកស្របដងផ្លូវ</td><td>៧០០៛/ជម$^2$/ឆ្នាំ</td><td>១ ៤០០៛</td><td rowspan="2">បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ</td></tr>
<tr><td>ខ</td><td>មានពន្លឺកែងដងផ្លូវ</td><td>១ ០០០៛/ជម$^2$/ឆ្នាំ</td><td>២ ០០០៛</td></tr>
</table>

| ៧- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៣ នៃអនុក្រឹត្យនេះ | | | | |
|---|---|---|---|---|
| ក | ដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូននានា | ១ ៥០០៛/ដម^២^/ឆ្នាំ | ៣ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |

**មាត្រា៥ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៦ កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ